មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# គោលនយោបាយសង្ខេប
# ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា

## ១. សាវតារ

នៅក្នុងប្រទេសកម្ពុជា ការរំលោភបំពានជាប្រព័ន្ធលើសិទ្ធិដីធ្លីគឺជាបញ្ហាសិទ្ធិមនុស្សដែលមានសភាពរីករាលដាលជាខ្លាំង។ ជាពិសេស ជនជាតិដើមភាគតិចកំពុងបាត់បង់ដីរបស់ពួកគេក្នុងអត្រាមួយគួរឱ្យព្រួយបារម្ភខ្លាំង ដោយសារតែការកាប់ទន្រ្ទានព្រៃ ការធ្វើឧស្សាហកម្ម និស្សារណកម្ម គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានដី។ ជាការឆ្លើយតបក្នុងការប្រឈមនេះ រដ្ឋាភិបាលបានទទួលស្គាល់សិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិច។ ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបានទទួលស្គាល់ជាក់លាក់លើទស្សនទាននៃ កម្មសិទ្ធិដីសមូហភាព ដោយអនុញ្ញាតឲ្យសហគមន៍ជនជាតិដើមភាគតិចចុះបញ្ជីដីសហគមន៍ជាផ្លូវការតាមប័ណ្ណកម្មសិទ្ធិដីសមូហភាព។

ការទទួលស្គាល់នេះមានសារៈសំខាន់ខ្លាំងណាស់ពីព្រោះការបាត់បង់ដីនិងការមិនមានកម្មសិទ្ធិគំរាមកំហែងដល់អត្ថិភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជាដែលមានចំនួនជាង ១៩០.០០០នាក់[1]។ តាមប្រពៃណីជនជាតិដើមភាគតិចនៅកម្ពុជាចិញ្ចឹមជីវិតតាមរយៈការដាំដុះលើដីព្រៃប្រើប្រាស់បច្ចេកទេសដែលគេហៅថាការធ្វើកសិកម្មវិលជុំ[2]ក៏ដូចជាការបរបាញ់សត្វព្រៃ និងប្រមូលអនុផលព្រៃឈើ។ ជាងនេះទៀត ជំនឿ ប្រពៃណីនិងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិចបានផ្សារទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយដីដែលជាទីគោរពសក្ការៈដល់ដួងវិញ្ញាណក្ខន្ធនៃដូនតារបស់ពួកគាត់និងអារក្ខអ្នកតា។

ទោះបីជាដីដើរតួសំខាន់សម្រាប់សហគមន៍ជនជាតិដើមភាគតិច និងការមានក្របខណ្ឌច្បាប់ដែលការពារសិទ្ធិដីធ្លីរបស់ពួកគាត់ក៏ដោយក៏ក្នុងការអនុវត្តជាក់ស្តែងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពត្រូវការពេលវេលាវែងនិងមានភាពស្មុគស្មាញខ្លាំង ហើយជារឿយៗ ការពន្យារពេលវេលាវែងឆ្ងាយនេះគឺដោយសារកង្វះឆន្ទៈនយោបាយផងដែរ។ ជាងនេះទៀត កង្វះការអនុវត្តច្បាប់បាននាំឲ្យសហគមន៍ជនជាតិដើមភាគតិចបាត់បង់ដីសហគមន៍និងធនធានធម្មជាតិយ៉ាងឆាប់រហ័ស។ នៅពេលសរសេររបាយការណ៍នេះ មានសហគមន៍ជនជាតិដើមភាគ

[1] វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា “ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា” (មេសា ២០០៦)

[2] ក៏ត្រូវគេស្គាល់ថាជាកសិកម្មវិលជុំ

តិចតែ ១១ ប៉ុណ្ណោះ ដែលបានទទួលប័ណ្ណកម្មសិទ្ធិz ដីសមូហភាព។

**រូបទី១៖ ផែនទីទីតាំងស្រាវជ្រាវទិន្នយដើម**




គោលនយោបាយសង្ខេបនេះនឹងរៀបរាប់អំពីរបកគំហើញចម្បងៗពីការស្រាវជ្រាវដែលធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក") ទៅលើការប្រឈម នៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ព្រមទាំងធ្វើសេចក្តីសន្និដ្ឋាននិងផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដល់ភាគីពាក់ព័ន្ធទាំងឡាយ។ ព័ត៌មានលម្អិតអាចស្វែងរកបានតាមរយៈរបាយការណ៍របស់ ម.ស.ម.ក ដែលមានចំណងជើងថា "*ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា*"[3]។

គោលនយោបាយសង្ខេបនេះតាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធធ្វើការក្នុងការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ២. ការប្រឈមក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព

ការស្រាវជ្រាវនេះបង្ហាញថា ប្រជាសហគមន៍ជនជាតិដើមភាគតិចជាច្រើនខ្វះការយល់ដឹងអំពី

[3] ម.ស.ម.ក "ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា" (របាយការណ៍) (កុម្ភៈ ២០១៦) http://bit.ly/1QRHPs7

ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពនិងលក្ខខណ្ឌតម្រូវ។ ប្រការនេះមិនមានអ្វីជាការភ្ញាក់ផ្អើលទេ ដោយសារនីតិវិធីសម្រាប់ការចុះបញ្ជីនេះមានលក្ខណៈទូលំទូលាយនិងស្មុគស្មាញពេកគឺសហគមន៍ត្រូវតែបំពេញបីដំណាក់កាល ហើយដំណាក់កាលនីមួយៗ រួមមានជំហានជាច្រើនដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព ៖ ទី១ សហគមន៍ត្រូវទទួលបានអត្តសញ្ញាណកម្មផ្លូវការដោយមានការទទួលស្គាល់នូវ *"វប្បធម៌ប្រពៃណី"* ពីក្រសួងអភិវឌ្ឍន៍ជនបទ បន្ទាប់មកត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ជា *"នីតិបុគ្គល"* ជាមួយនឹងក្រសួងមហាផ្ទៃ ហើយជាចុងក្រោយ សហគមន៍ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ដើម្បីចុះបញ្ជីដីសមូហភាពដើម្បីចុះបញ្ជីរបស់ពួកគេនិងដើម្បីឲ្យចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព។

ខណៈដែលកង្វះការយល់ដឹងអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងចំណោមសហគមន៍ជាការដែលយើងអាចយល់បាននោះកង្វះការយល់ដឹង នៅក្នុងចំណោមអាជ្ញាធរមូលដ្ឋាននៅតំបន់ជនជាតិដើមភាគតិច គឺជាការព្រួយបារម្ភមួយបន្ថែមទៀត។ ការខ្វះខាតចំណេះដឹងគ្រប់គ្រាន់នៃដំណើរការចុះបញ្ជីដីនោះបណ្តាលឲ្យអាជ្ញាធរទាំងនោះមិនអាចបំពេញអាណត្តិរបស់ខ្លួនក្នុងការបម្រើផលប្រយោជន៍ជូនពលរដ្ឋនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។

*"ខ្ញុំមិនបានដឹងអំពីដំណើរការចុះបញ្ជីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ.....រដ្ឋាភិបាលមិនដែលបានផ្តល់ព័ត៌មានឬការបណ្តុះបណ្តាលណាមួយអំពីរបៀបជួយដល់ជនជាតិដើមភាគតិចជាមួយនិងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទេ។"* (ការលើកឡើងរបស់មេឃុំម្នាក់)

ជាងនេះទៀត តម្លៃក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ត្រូវបានរកឃើញថាជាបញ្ហាចម្បងរបស់សហគមន៍ក្នុងការចុះបញ្ជីដីសហគមន៍។ ទោះបីជាក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់បានបញ្ជាក់ថារដ្ឋាភិបាលបានរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការនោះក៏ដោយក៏ការស្រាវជ្រាវបានបញ្ជាក់ថាមិនមានថវិកាគ្រប់គ្រាន់ត្រូវបានផ្តល់ទៅស្ថាប័នពាក់ព័ន្ធនោះទេ (ការស្រាវជ្រាវបង្ហាញថាក្រសួងអភិវឌ្ឍន៍ជនបទបានស្នើទឹកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន)ដុល្លាសហរដ្ឋអាមេរិកពីសហគមន៍ និងដៃគូអភិវឌ្ឍដើម្បីដំណើរការក្នុងដំណាក់កាលទីមួយ)។

ដូច្នេះចំពោះសហគមន៍ជនជាតិដើមភាគតិចណាដែលមានបំណងចង់ទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅដំណាក់កាលដំបូងនេះ ពួកគេត្រូវស្វែងរកការគាំទ្រខាងក្រៅពីអង្គការសង្គមស៊ីវិល ឬដៃគូអភិវឌ្ឍន៍ផ្សេងទៀតដើម្បីជួយផ្គត់ផ្គង់លើការចំណាយដ៏ច្រើនក្រាស់ក្រែលនេះ។

កង្វះឆន្ទៈនយោបាយក្នុងការជួយសហគមន៍ក្នុងដំណើរការនេះនិងកង្វះផ្តល់កិច្ចការពារដីធ្លីក្នុងសហគមន៍របស់ពួកគេជាផ្លូវការត្រូវបានបង្ហាញបន្ថែមទៀតដោយសារការពន្យារពេលក្នុងដំណាក់កាលនីមួយៗក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពអាចប្រើពេលជាច្រើនឆ្នាំ។ ការពន្យារពេលបែបនេះគឺជាបញ្ហាសំខាន់ណាស់ព្រោះពុំមានសុវត្ថិភាពក្នុងការកាន់កាប់ដីរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពជាដើម ដូច្នេះមានតែវិធានការការពារបណ្តោះ

អាសន្នជានាសុវត្ថិភាពការកាន់កាប់ដីប៉ុណ្ណោះដែលជាជម្រើសចុងក្រោយដើម្បីការពារដីក្នុងដំណើរការនេះ។ ជារឿយៗសហគមន៍ ត្រូវតែការពារដីរបស់ខ្លួនពីការចាប់អារម្មណ៍ដោយអ្នកខាងក្រៅរយៈពេលជាច្រើនឆ្នាំ មុនពេលសិទ្ធិស្របច្បាប់របស់ខ្លួនត្រូវបានទទួលស្គាល់។

*"ការលំបាកចម្បងគឺរដ្ឋាភិបាល។ ពួកគេជាអ្នកផ្តល់សម្បទាន។ ពួកគេរាំងស្ទះក្នុងការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់យើង។ គ្មានអ្នកណាផ្សេងទៀតទេ។"*
(ការលើកឡើងរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចមួយរូប)

## ៣. ការប្រឈមពីអាជ្ញាធរមូលដ្ឋាន

ការប៉ុនប៉ងរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការការពារនិងចុះបញ្ជីដីសហគមន៍ ជាទូទៅជួបនឹងកង្វះការគាំទ្រយ៉ាងខ្លាំងពីអាជ្ញាធរមូលដ្ឋាន។ ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថាកង្វះខាតការគាំទ្រពីអាជ្ញាធរមូលដ្ឋាន អាចត្រូវបានពន្យល់តាមរយៈការសមគំនិតជាមួយវិស័យឯកជន ដែលមានការចាប់អារម្មណ៍ទៅលើដីធ្លីនិងធនធានធម្មជាតិរបស់សហគមន៍។ ក្រៅពីមិនបានជួយដល់សហគមន៍ដែលបានខិតខំប្រឹងប្រែងនោះ នៅពេលដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចព្យាយាមការពារដីរបស់ខ្លួននិងចាត់វិធានការក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ សហគមន៍ទាំងនេះបែរជាទទួលការធ្វើទុក្ខបុកម្នេញដោយពាក្យសម្តី ទៅលើរាងកាយនិងតាមផ្លូវតុលាការពីសំណាក់អាជ្ញាធរមូលដ្ឋានទៅវិញ។ ជាងនេះទៅទៀត អាជ្ញាធរមូលដ្ឋានបានដាក់គំនាបជាប្រចាំទៅលើសហគមន៍ជនជាតិដើមភាគតិចឲ្យទទួលយកប័ណ្ណកម្មសិទ្ធិដីឯកជនទៀតផង ព្រមទាំងបានគំរាមកំហែងថាប្រសិនបើពួកគេមិនព្រមទទួលយកប័ណ្ណកម្មសិទ្ធិដីឯកជនពួកគេនឹងបាត់បង់ដីហើយគ្មានសល់អ្វីទេ។

*អាជ្ញាធរមិនដែលគាំទ្រពួកយើងទេ ពួកគេច្រានចោលសំណើរបស់ពួកយើងក្នុងការជួយយើងចុះបញ្ជីជានីតិបុគ្គល។"* (ការលើកឡើងរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចមួយរូប)

សូម្បីតែនៅក្នុងករណីដ៏កម្រដែលអាជ្ញាធរមូលដ្ឋានចង់គាំទ្រដល់សហគមន៍ក៏ដោយ ក៏ពួកគេមិនមានសមត្ថភាពឬសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការចាត់វិធានការសម្រាប់គាំទ្រនោះដែរ។ តាមរយៈអំណាចតិចតួចស្តួចស្តើងនោះ អាជ្ញាធរមូលដ្ឋានបានត្រឹមតែធ្វើតាមបញ្ជាពីថ្នាក់លើប៉ុណ្ណោះ ហើយភាគច្រើនភ័យខ្លាចថាការមិនធ្វើតាមថ្នាក់លើនឹង បណ្តាលឲ្យមានការដកចេញពីតួនាទី។

*"ខ្ញុំខ្លាចថាថ្ងៃណាមួយគេដកខ្ញុំចេញពីក្រុមប្រឹក្សាឃុំ។ គេស្គាល់ខ្ញុំថាខ្ញុំជាមនុស្សសកម្មក្នុងការគាំទ្រសហគមន៍និងមិនគាំទ្រក្រុមហ៊ុនទេ ដូច្នេះខ្ញុំគឺជាគោលដៅរបស់ពួកគេ"។*
(ការលើកឡើងរបស់សមាជិកក្រុមប្រឹក្សាឃុំមួយរូប)

## ៤. ការប្រឈមចេញពីតួអង្គសាជីវកម្ម

ការស្រាវជ្រាវបង្ហាញថាក្រុមហ៊ុនច្រើនតែសមគំនិតគ្នាមួយអាជ្ញាធរដើម្បីអនុញ្ញាតឲ្យពួកគេប្រតិបត្តិការសម្បទានដីសេដ្ឋកិច្ច ដោយមិនចាំបាច់អនុវត្តតាមលក្ខខណ្ឌតម្រូវនោះទេនិងទប់ស្កាត់មិនឲ្យមានការគាំទ្រណាមួយដល់សហគមន៍ជនជាតិដើមភាគតិចដែលអាចរំខានដល់ប្រតិបត្តិការពាណិជ្ជកម្មរបស់ពួកគេ។ ជារឿយៗ ពួកគេរួមគំនិតគ្នាដោយផ្ទាល់ក្នុងការធ្វើទុក្ខបុកម្នេញដល់សមាជិកសហគមន៍ជនជាតិដើមភាគតិចដោយការបណ្តេញពួកគេចេញ

ពីដីធ្លីដោយបង្ខំនិងបំផ្លាញទំនុកចិត្តរបស់សហគមន៍ ដែលការធ្វើបែបនេះនឹងបំផ្លាញសមត្ថភាពគស្វ័មតិការពារដីធ្លីរបស់ពួកគេ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនដែលកំពុងប្រតិបត្តិនៅក្នុងតំបន់ជនជាតិដើមភាគតិចនៅកម្ពុជាច្រើនតែរំខានរារាំងដល់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះតាមរយៈការចាប់យកដីនិងការសេមគំនិតក្នុងការកាប់ឈើខុសច្បាប់នៅក្នុងតំបន់សម្បទានរបស់ពួកគេ និងរារាំងសហគមន៍មិនឲ្យមានលទ្ធភាពក្នុងការកំណត់ព្រំដីទៅលើដីដែលធ្លាប់ជាដីប្រពៃណីរបស់ពួកគេ។

*"ពួកគេកាប់ឈើខុសច្បាប់ហើយឥឡូវនេះគេមិនអាចធ្វើផែនទីដីបានទៀតទេ ប្រសិនបើគេសួរថា "ដីសហគមន៍នៅកន្លែងណា?" យើងមិនមានភស្តុតាងបង្ហាញទេ ដោយសារតែយើងបាត់ព្រំកំណត់អស់ហើយ"*។ (ការលើកឡើងរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចមួយរូប)

## ៥. ការប្រឈមនៅក្នុងសហគមន៍

រូបទី២៖ ការយល់ដឹងអំពីសិទ្ធិជាម្ចាស់ដីតាមផ្លូវច្បាប់




ការស្រាវជ្រាវនេះបង្ហាញច្បាស់ថាមិនមែនរាល់សមាជិកសហគមន៍ជនជាតិដើមភាគតិចទាំងអស់សុទ្ធតែដឹងអំពីសិទ្ធិធ្វើជាម្ចាស់ដីតាមផ្លូវច្បាប់នោះទេ។

ជារួមគឺការយល់ដឹងក្នុងចំណោមសហគមន៍អំពីច្បាប់ភូមិបាលនៅមានកម្រិតត្រឹម ៦២% និងអំពីសិទ្ធិដីធ្លីមាន ៧៧%។ ទោះជាយ៉ាងណា គួរកត់សម្គាល់ថាប្រជាសហគមន៍ដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះគឺជាតំណាងសហគមន៍និងជាសមាជិកសហគមន៍មួយចំនួនដែលអាចមានចំណេះដឹងនៅក្នុងវិស័យនេះរួចទៅហើយ។ ដូច្នេះហើយ កម្រិតនៃការយល់ដឹងនេះមិនតំណាងឲ្យសហគមន៍ទាំងមូលនោះទេ។

ទាក់ទងនឹងប្រភេទកម្មសិទ្ធិដីធ្លី សមាជិកសហគមន៍ជនជាតិដើមភាគតិចជាច្រើនបានសំដែងថាខ្លួនចង់បានប័ណ្ណកម្មសិទ្ធិដី សមូហភាពជាជាងកម្មសិទ្ធិដីឯកជន។ ក៏ប៉ុន្តែ ការស្រាវជ្រាវនេះបានបង្ហាញអំពីកង្វះឯកភាពក្នុងចំណោមសហគមន៍មួយចំនួនទាក់ទងនឹងការការពារផ្នែកច្បាប់ដែលពួកគេចង់បានសម្រាប់ដីរបស់ខ្លួន។

រូបទី៣ ៖ ការប្រាថ្នាចង់បានកម្មសិទ្ធិដីក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច




នៅក្នុងសហគមន៍មួយ តំណាងសហគមន៍ទាំងអស់សុទ្ធតែបញ្ជាក់អំពីការប្រាថ្នាចង់បានកម្មសិទ្ធិដីឯកជន ក៏ប៉ុន្តែបានពន្យល់ថាពួកគេគ្មានដីសហគមន៍នៅសល់សម្រាប់ចុះបញ្ជីតាមដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទៀតទេ ដោយសារតែការចាប់ច្បាមយកដីកើតមានពាសពេញក្នុងតំបន់។ កង្វះឯកភាពក្នុងចំណោមសហគមន៍ត្រូវបានរកឃើញថាជាមូលហេតុចម្បងដែលធ្វើឲ្យសហគមន៍មិនមានលទ្ធភាពការពារដីរបស់ខ្លួន។ នៅក្នុងសហគមន៍មួយផ្សេងទៀត តំណាងម្នាក់បានថ្លែងពីការ

ប្រាថ្នាចង់បានកម្មសិទ្ធិដីឯកជន ដោយគាត់បានពន្យល់ថាគាត់នឹងអាចប្រើប័ណ្ណកម្មសិទ្ធិនោះទៅខ្ចីលុយពីធនាគារបាន (តាមច្បាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពមិនអាចយកមកប្រើប្រាស់ក្នុងគោលបំណងបែបនេះឡើយ)។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានសង្កេតឃើញថា ក្នុងអំឡុងពេលនៃដំណើរការចុះបញ្ជីដី ប្រជាសហគមន៍មួយចំនួនបានសម្រេចចិត្តឈប់ចូលរួមទាមទារប័ណ្ណកម្មសិទ្ធិដីសមូហភាព ហើយត្រឡប់មកជាស្នើសុំប័ណ្ណកម្មសិទ្ធិឯកជនជំនួសវិញ។ ការបន្ទាយពេលក្នុងដំណើរការនេះចំណាយពេលយូរនិងធនធានច្រើន ព្រោះក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ត្រូវត្រឡប់ទៅកាន់សហគមន៍និងធ្វើការវាយតម្លៃដីនោះជាថ្មីឡើងវិញ។

ប្រាកដណាស់ថា វាមានផលប្រយោជន៍សម្រាប់គ្រួសារជនជាតិដើមភាគតិចដែលបានទទួលប័ណ្ណកម្មសិទ្ធិដីឯកជនដោយស្របច្បាប់ គឺវាបានផ្តល់នូវការការពារភ្លាមៗទៅលើដីរបស់ពួកគេហើយវាអនុញ្ញាតឲ្យម្ចាស់អាចប្រើជារបស់បញ្ចាំក្នុងការខ្ចីលុយពីធនាគារ។ ក៏ប៉ុន្តែ ជាញឹកញាប់គ្រួសារជនជាតិដើមភាគតិចសម្រេចចិត្តទទួលយកកម្មសិទ្ធិដីឯកជនក្រោមសម្ពាធពីអាជ្ញាធរមូលដ្ឋាន ដោយមិនបានទទួលព័ត៌មានពេញលេញអំពីផលវិបាកឡើយ និងនៅចំពោះមុខនៃការទន្ទ្រានកាន់តែខ្លាំងឡើងទៅលើដីរបស់ពួកគេ។ នៅក្នុងបរិបទនេះអាចអោយយើងសន្និដ្ឋានបានថា គ្រួសារទាំងនោះជាច្រើនបានព្រមទទួលយកកម្មសិទ្ធិដីឯកជនក្រោមការគំរាមកំហែង។

*"បើយើងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព យើងនឹងមានដីប្រពៃណីរបស់យើងគ្រប់ប្រភេទ។ ប្រសិនបើយើងបានកម្មសិទ្ធិដីឯកជននោះ គ្រួសារខ្លះនឹងបាត់បង់ដីរបស់ពួកគេក្នុងពេលអនាគតដូចជានៅពេលដែលពួកគេមានបញ្ហាលុយកាក់ ពួកគេអាចលក់ដីឯកជននោះ។ ដូច្នេះប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺអាចការពារដីសម្រាប់មនុស្សជំនាន់ក្រោយ។"* (ការលើកឡើងតំណាងសហគមន៍ជនជាតិដើមភាគតិចមួយរូប)

## ៦. ការប្រឈមពីអង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍នានា

ថ្វីបើអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការផ្សេងទៀតដែលធ្វើការគាំទ្រការចុះបញ្ជីកម្មសិទ្ធិដីសហគមន៍របស់សហគមន៍ជនជាតិដើមភាគតិចមានចេតនាល្អក៏ដោយ ក៏ពួកគេអាចបង្កជាបញ្ហាអចេតនា ហើយប្រការនេះក៏អាចមានផលជះដល់សហគមន៍ជនជាតិដើមភាគតិចដែរ។ បញ្ហាចម្បងដែលត្រូវបានរកឃើញនោះគឺការប្រកួតប្រជែង ជាជាងការសហការក្នុងចំណោមអង្គការទាំងនោះ។

*"យើងតែងតែរិះគន់ចំណុចខ្សោយរបស់រដ្ឋាភិបាល ប៉ុន្តែយើងកម្ររិះគន់ខ្លួនឯងណាស់ដែលនេះគឺជាភាពខ្វះចន្លោះរបស់សង្គមស៊ីវិល...ឧបសគ្គមួយក្នុងចំណោមឧបសគ្គចម្បងៗគឺភាពខ្វះចន្លោះក្នុងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល"*។ (ការលើកឡើងរបស់តំណាងអង្គការសង្គមស៊ីវិលមួយរូប)

## ៧. អនុសាសន៍

*"នៅពេលដែលយើងនឹងត្រូវជម្លៀសចេញពីទីនេះ អ្វីៗទាំងអស់ដែលពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់យើងនឹងត្រូវបាត់បង់អស់។ វប្បធម៌និងប្រពៃណីរបស់យើង ពឹងផ្អែកលើដី។ យើងនឹងក្លាយទៅជា*

*ប្រជាជនខ្មែរទូទៅ យើងលែងជាជនជាតិដើមភាគតិចដែងទៀតហើយ*។ (ការលើកឡើងរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចមួយរូប)

ការបណ្តេញជនជាតិដើមភាគតិចចេញពីដីរបស់ពួកគាត់ជាការគំរាមកំហែងដល់អត្ថិភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ប៉ុន្តែដំណើរការក្នុងការការពារដីនេះរងការញាំញីដោយឧបសគ្គផ្នែកច្បាប់ នយោបាយនិងសង្គម។

ជាមួយគ្នានេះ ម.ស.ម.ក សូមផ្តល់នូវអនុសាសន៍ ដល់ភាគីពាក់ព័ន្ធនានាដូចតទៅៈ

***រាជរដ្ឋាភិបាលកម្ពុជា***

- បែងចែកកញ្ចប់ថវិកាឲ្យបានគ្រប់គ្រាន់សម្រាប់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងពង្រឹងសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធដើម្បីពន្លឿនដំណើរការនេះ
- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ដើម្បីធានាឲ្យមានការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ
- បង្កើនការយល់ដឹងអំពីប័ណ្ណកម្មសិទ្ធិដីសមូហភាពនិងប័ណ្ណកម្មសិទ្ធិដីឯកជន ព្រមទាំងផលប្រយោជន៍/ផលវិបាករបស់វា ទៅដល់សហគមន៍ជនជាតិដើមភាគតិច
- ផ្សព្វផ្សាយព័ត៌មានអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ដល់សហគមន៍
- បញ្ឈប់ការអនុម័តសម្បទាននិងគម្រោងអភិវឌ្ឍន៍បន្ថែមទៀតនៅក្នុងតំបន់ជនជាតិដើមភាគតិច រហូតដល់ព្រំប្រទល់ដីជនជាតិដើមភាគតិចទាំងអស់ត្រូវបានកំណត់ជាមុនសិន
- កែប្រែវិធានការការពារបណ្តោះអាសន្នដើម្បីធានាសិទ្ធិកាន់កាប់ដីរបស់សហគមន៍ក្នុងដំណាក់កាលដំបូងនៃការស្នើសុំចុះបញ្ជីដីសមូហភាព
- បញ្ឈប់ការដាក់គំនាបដោយបង្ខំទៅលើជនជាតិដើមភាគតិចឲ្យទទួលយកកម្មសិទ្ធិដីឯកជន
- បញ្ឈប់ការគំរាមកំហែងនិងការធ្វើទុក្ខបុកម្នេញទៅលើសកម្មជនសហគមន៍ជនជាតិដើមភាគតិចដែលតស៊ូមតិដើម្បីការពារសិទ្ធិដីធ្លីរបស់ខ្លួន

***ក្រុមហ៊ុន***

- គោរពឲ្យបានខ្ជាប់ខ្ជួនតាមច្បាប់ជាតិនិងច្បាប់អន្តរជាតិនៅក្នុងប្រតិបត្តិអាជីវកម្មទាំងអស់
- ជៀសវាងការបង្កឬរួមចំណែកដល់ការប៉ះពាល់សិទ្ធិមនុស្ស និង
- ដោះស្រាយនិងផ្តល់សំណងសមរម្យសម្រាប់ការប៉ះពាល់បែបនេះនៅពេលដែលវាកើតឡើង

***អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍***

- ពង្រឹងកិច្ចសហប្រតិបត្តិការឲ្យកាន់តែប្រសើរឡើងជាមួយអង្គការនានាដែលកំពុងជួយជ្រោមជ្រែងដល់សហគមន៍ជនជាតិដើមភាគតិច
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជំនួយចាំបាច់ដល់ស្ថាប័នរដ្ឋពាក់ព័ន្ធពង្រឹងសមត្ថភាពដើម្បីឲ្យស្ថាប័នទាំងនោះគាំទ្រសហគមន៍ជនជាតិដើមភាគតិចឲ្យបានកាន់តែប្រសើរ

- ផ្តល់កម្មវិធីពង្រឹងសមត្ថភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចដើម្បីបង្កើនចំណេះដឹង និងទំនុកចិត្ត
- ជានាថាអ្នកទទួលបានពីការបណ្តុះបណ្តាល រួមមានសមាជិកសហគមន៍ ជាជាងមានតែតំណាងសហគមន៍ និង
- សម្រួលការចងបណ្តាញរវាងសហគមន៍ជនជាតិដើមភាគតិចនានាដើម្បីពង្រឹងឲ្យមានសាមគ្គីភាព

***សហគមន៍***

- ពង្រឹងឯកភាពសហគមន៍តាមរយៈការរៀបចំកិច្ចប្រជុំទៀងទាត់ និងតាមរយៈការជំរុញយុវជនជំនាន់ក្រោយឲ្យចូលរួមនៅក្នុងសកម្មភាពសហគមន៍
- ធានាថាសមាជិកសហគមន៍ដែលចូលរួមវគ្គបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិលផ្សព្វផ្សាយចំណេះដឹងដែលទទួលបានដល់សមាជិកសហគមន៍ដទៃទៀត

**ឧបត្ថម្ភដោយ**

សហភាពអឺរ៉ុប

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖+៨៥៥ (០) ២៣ ៧២៦ ៩០១

ទូរសារ៖ +៨៥៥ (០) ២៣ ៧២៦ ៩០២

អ៊ីម៉ែល ៖ info@cchrcambodia.org

គេហទំព័រ ៖ www.cchrcambodia.org

CC BY NC SA